ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..៤១១......សហវ.ប្រកអន្តរ

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការផ្តល់សេវាសាធារណៈលើការជូនដំណឹង ការចេញវិញ្ញាបនបត្រជាមុន និងការចុះបញ្ជីការរួមបញ្ចូលគ្នានៃធុរកិច្ច

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ ស្ដីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច
- បានឃើញប្រកាសអន្តរក្រសួងលេខ៣១៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

សេវាសាធារណៈដែលផ្ដល់ដោយក្រសួងពាណិជ្ជកម្ម លើការជូនដំណឹង ការចេញវិញ្ញាបនបត្រជាមុន និងការចុះបញ្ជីការរួមបញ្ចូលគ្នានៃធុរកិច្ច ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា និងរយៈពេលអតិបរមានៃការផ្ដល់សេវា ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដែលកំណត់ដូចខាងក្រោម៖

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | ១- ការជូនដំណឹងជាមុនអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច | | | |
| ១ | - ធុរកិច្ចទូទៅ | ៨ ០០០ ០០០ | ១៥០ថ្ងៃ | អចិន្ត្រៃយ៍ |
| ២ | - ធុរកិច្ចដែលមានភាគីណាមួយជាក្រុមហ៊ុនធានារ៉ាប់រង ឬក្រុមហ៊ុនមូលបត្រ | ១០ ០០០ ០០០ | ១៥០ថ្ងៃ | អចិន្ត្រៃយ៍ |
| ៣ | - ធុរកិច្ចដែលមានភាគីណាមួយជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ | ១២ ០០០ ០០០ | ១៥០ថ្ងៃ | អចិន្ត្រៃយ៍ |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | ២- ការចេញវិញ្ញាបនបត្រជាមុន ចំពោះការរួមបញ្ចូលគ្នានៃធុរកិច្ច | | | |
| ៤ | - ធុរកិច្ចទូទៅ | ១០ ០០០ ០០០ | ១២០ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥ | - ធុរកិច្ចដែលមានភាគីណាមួយជាក្រុមហ៊ុនធានារ៉ាប់រង ឬក្រុមហ៊ុនមូលបត្រ | ១២ ០០០ ០០០ | ១២០ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦ | - ធុរកិច្ចដែលមានភាគីណាមួយជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ | ១៤ ០០០ ០០០ | ១២០ថ្ងៃ | អចិន្ត្រៃយ៍ |
| | ៣- ការចុះបញ្ជីការរួមបញ្ចូលគ្នានៃធុរកិច្ច | | | |
| ៧ | - ធុរកិច្ចទូទៅ | ៦០០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ៨ | - ធុរកិច្ចដែលមានភាគីណាមួយជាក្រុមហ៊ុនធានារ៉ាប់រង ឬក្រុមហ៊ុនមូលបត្រ | ៨០០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ៩ | - ធុរកិច្ចដែលមានភាគីណាមួយជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ | ១ ០០០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| | ៤- ការជូនដំណឹងជាក្រោយអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច | | | |
| ១០ | - ធុរកិច្ចទូទៅ | ៤០០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ១១ | - ធុរកិច្ចដែលមានភាគីណាមួយជាក្រុមហ៊ុនធានារ៉ាប់រង ឬក្រុមហ៊ុនមូលបត្រ | ៦០០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ១២ | - ធុរកិច្ចដែលមានភាគីណាមួយជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ | ៨០០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |

**ប្រការ២ .–**

ទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការផ្ដល់សេវាសាធារណៈ ដែលចែងនៅក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ ត្រូវកំណត់ដោយក្រសួងពាណិជ្ជកម្ម និង/ ឬ គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា។

**ប្រការ៣ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ... ខែ ... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ... ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ